ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សិក្ខាសាលា

ក្រុមប្រឹក្សាបច្ចេកទេសលើកទី០៩របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩

រៀបចំដោយ: នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយៈ ថវិកាជាតិ

## ១. សេចក្តីផ្តើម៖

នៅព្រឹកថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី០៩ ក្រោមការដឹកនាំរបស់ **ឯកឧត្តម ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួង ស្ថាប័ន ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើការងារមេរោគអេដស៍និងជំងឺអេដស៍។កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភពីថវិកាជាតិ។

## ២. គោលបំណងនៃកិច្ចប្រជុំ៖

ដើម្បីពិនិត្យមើលរបាយការណ៍វឌ្ឍនភាព និងទិសដៅបន្តក្នុងការឆ្លើយតបទៅនឹងការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ព្រមទាំងពិភាក្សាសម្របសម្រួលការងារបច្ចេកទេសតាមរបៀបវារៈ ដូចខាងក្រោម៖

- មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំ
- បទបង្ហាញពីរបាយការណ៍ប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បទបង្ហាញស្តីអំពីវឌ្ឍនភាពនៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមក្រុមប្រឈមមុខខ្ពស់ ។
- បទបង្ហាញអំពីការរៀបចំផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ (ឆ្នាំ២០១៩-២០២៣)។
- និងបញ្ហាផ្សេងៗ

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ៖

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណដល់សមាជិក សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ដែលបានអញ្ជើញចូលរួមនាពេលនេះ ហើយកិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈដែលបានគ្រោងទុក។






**ប្រធានបទទី១៖**បទបង្ហាញស្ដីអំពីវឌ្ឍនភាពនៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមក្រុមប្រឈមមុខខ្ពស់ បង្ហាញដោយ លោកវេជ្ជ. **ឡាន វណ្ណសេខ** អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។

បទបង្ហាញបានឱ្យដឹងថា បច្ចុប្បន្នចំនួនប៉ាន់ស្មាននៃអ្នករស់នៅជាមួយមេរោគអេដស៍នៅឆ្នាំ២០១៨ មាន៧៤,២៩៨នាក់ ក្នុងនោះចំនួន ៥៩,៨៣៧នាក់ បានកំពុងព្យាបាល និង១៤,០០០នាក់ទៀតមិនទាន់ដឹងពីស្ថានភាពមេរោគអេដស៍របស់ខ្លួន។

បើយោងទៅលើការសិក្សា AEM ២០១៦ អត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមក្រុមគោលដៅបានឱ្យដឹងថា៖

- ក្នុងចំណោមប្រជាជនពេញវ័យអាយុពី ១៥ ដល់ ៤៩ឆ្នាំ មានអត្រាប្រេវ៉ាឡង់ ០.៦%
- ក្រុមស្ត្រីបម្រើសេវាកម្សាន្តសប្បាយមានអត្រាប្រេវ៉ាឡង់ ៣.២% (ការសិក្សា AEM 2016)
- បុរសរួមភេទជាមួយបុរសមានអត្រាប្រេវ៉ាឡង់ ២.៣%(ការសិក្សា AEM 2014)
- ក្រុមអ្នកបំប្លែងភេទមានអត្រាប្រេវ៉ាឡង់ ៥.៩% (ការសិក្សា AEM 2016)
- ក្រុមអ្នកប្រើគ្រឿងញៀនមានអត្រាប្រេវ៉ាឡង់ ៥.៧% (ការសិក្សា AEM 2017)
- ក្រុមអ្នកចាក់គ្រឿងញៀនមានអត្រាប្រេវ៉ាឡង់ ១៥.២% (ការសិក្សា AEM 2017)

តាមការសិក្សា AEM ២០១៩ បានបង្ហាញថា ចំនួនប៉ាន់ប្រមាណទៅលើក្រុមគោលដៅនីមួយៗ៖

- បុរសរួមភេទជាមួយបុរសមានប្រមាណ ៧២,២០០នាក់
- ក្រុមស្ត្រីបម្រើសេវាកម្សាន្តសប្បាយមានប្រមាណ ៤២,១០០នាក់
- ក្រុមអ្នកបំប្លែងភេទមានប្រមាណ ៣,២០០នាក់
- ក្រុមអ្នកចាក់គ្រឿងញៀនមានប្រមាណ ៣,២០០នាក់
- ក្រុមអ្នកប្រើគ្រឿងញៀនមានប្រមាណ ១៨,០០០នាក់

តាមរយៈការសិក្សា Joint Program Reviews របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគយើងមានការប្រឈមមុខខ្ពស់ចំពោះយុវវ័យ ពិសេសអ្នកមានគូរស្នេហ៍ដោយសារអត្រានៃការប្រើប្រាស់ស្រោមអនាម័យមានកម្រិតទាប ២៧.២% ទាបជាងឆ្នាំ២០១០ ដែលមានអត្រា ៣៩.៤% និងយុវជនវ័យមានចំណេះដឹងមូលដ្ឋាននៅមានកម្រិត នេះបញ្ជាក់ឱ្យឃើញថាកន្លងមកដោយសារតែអង្គការដៃគូធ្វើការនៅក្នុងសហគមន៍ភាគច្រើនផ្ដោតសំខាន់ទៅលើការព្យាបាល និងធ្វើតេស្តឈាម មិនសូវផ្ដោតសំខាន់ការផ្ដល់ពីចំណេះដឹងទូទៅពីមេរោគអេដស៍ដល់យុវវ័យឡើយ។

ចំពោះក្រុមប្រជាជនគន្លឹះ មានអង្គការចំនួនពីរដែលកំពុងធ្វើសកម្មភាពលើ ១៨ខេត្ត-ក្រុង ដែលចែកជាពីរតំបន់គឺ តំបន់ខាងត្បូង និងខាងជើង គ្រប់គ្រងដោយអង្គការ KHANA មានចំនួន៨ខេត្ត (កោះកុង កំពង់ស្ពឺ កណ្ដាល ព្រៃវែង កំពង់ចាម ត្បូងឃ្មុំ កំពង់សោម និងក្រុងភ្នំពេញ) និងតំបន់ខាងជើងគ្រប់គ្រងដោយអង្គការ RHAC មានចំនួន ១០ខេត្ត (បាត់ដំបង ពោធិ៍សាត់ សៀមរាប ឧត្តរមានជ័យ កំពង់ឆ្នាំង កំពង់ធំ បន្ទាយមានជ័យ ព្រះវិហារ រតនគិរី និងប៉ៃលិន) ចំណែកខេត្តផ្សេងទៀត គ្រប់គ្រងដោយអង្គការ AHF (កំពង់សោម សៀមរាប និងស្វាយរៀង)។ ចំពោះកញ្ចប់នៃបទអន្តរាគមន៍ គឺការចុះ

អប់រំ ផ្សព្វផ្សាយផ្ទាល់នៅក្នុងសហគមន៍តាមរយៈអ្នកអប់រំផ្ទាល់ និងការស្វែងរកករណីឆ្លងថ្មីតាមរយៈមិត្តភក្ត្រ ការផ្តល់សារអប់រំស្តីពីការបង្ការមេរោគអេដស៍ ការចែកចាយស្រោមអនាម័យ និងការធ្វើតេស្តឈាមរកមេរោគអេដស៍ ។

❖ តារាងសេវាមេរោគអេដស៍ឆមាសទី១ ឆ្នាំ២០១៩ ៖

| ក្រុមប្រឈម / នាក់ | ចំនួនអ្នកតេស្ត | តេស្តប្រតិកម្ម | តេស្តបញ្ជាក់ | តេស្តវិជ្ជមាន | ចុះឈ្មោះក្នុងសេវា ART |
|---|---|---|---|---|---|
| EW | ២៤,១៩៣ | ៥០ | ៤៣ | ៣៣ | ៣៣ |
| MSM | ១៦,៩១៦ | ២០៤ | ១៧៦ | ១៧៣ | ១៧១ |
| TG | ៣,៣៤៤ | ៩០ | ៦៧ | ៦៧ | ៦៧ |

បញ្ហាប្រឈម៖

- មានការលំបាកក្នុងការធ្វើការជាមួយក្រុមប្រឈម ដោយសារតែម្ចាស់គ្រឹះស្ថានសេវាកម្សាន្តសប្បាយបានផ្តល់ពេលវេលាតិចតួចដល់អ្នកចុះអប់រំផ្ទាល់ក្នុងការរៀបចំវគ្គអប់រំ និងការធ្វើតេស្តឈាមរកមេរោគអេដស៍។
- ម្ចាស់គ្រឹះស្ថានសេវាកម្សាន្តសប្បាយបានអនុញ្ញាតឱ្យតែមានការផ្សព្វផ្សាយអប់រំ ប៉ុន្តែមិនអនុញ្ញាតឱ្យធ្វើតេស្តឈាមរកមេរោគអេដស៍ ។
- ក្រុមប្រឈមមុខមានការចល័តកន្លែងធ្វើការ និងរស់នៅផ្លាស់ប្តូរពីទីតាំងមួយទៅទីតាំងផ្សេងទៀត ជាពិសេសស្ត្រីបម្រើនៅតាមគ្រឹះស្ថានសេវាកម្សាន្តសប្បាយ។

ក្រោយពីបង្ហាញចប់ ឯកឧត្តមប្រធានអង្គប្រជុំ បានថ្លែងនូវការកោតសរសើរចំពោះមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដែលបានធ្វើបទបង្ហាញដ៏មានសារៈសំខាន់ជូនអង្គសិក្ខាសាលា ទន្ទឹមនឹងនោះ ឯកឧត្តមបានគូសបញ្ជាក់ថា វាជាក្តីបារម្ភចំពោះយុវវ័យ ពិសេសក្រុមបុរសរួមភេទជាមួយបុរស ដោយមានការកើនឡើងខ្ពស់។ តាមការសិក្សា AEM ២០១៩ បានបង្ហាញថាចំនួនប៉ាន់ប្រមាណ ក្រុមអ្នកបំប្លែងភេទ មាន៣២,០០នាក់ និងក្រុមបុរសរួមភេទជាមួយបុរសមានចំនួន៧២,២០០នាក់ ដូច្នេះត្រូវស្វែងរកយន្តការណាមួយដើម្បីដាក់ជូនថ្នាក់ដឹកនាំ ហើយយើងនឹងដោះស្រាយរួមគ្នាបន្តទៀត។ នាឱកាសនោះ ឯកឧត្តម ក៏បានស្នើដល់អង្គការជាដៃគូបន្តជួយ និងពង្រីកសកម្មភាពថែមទៀតឱ្យបាន ២៥ រាជធានី ខេត្ត។

បន្ទាប់មក លោកតំណាងលេខាធិការដ្ឋានអេដស៍រាជធានីភ្នំពេញ បានជម្រាបជូនអង្គសិក្ខាសាលាថាចំពោះកិច្ចសហការរបស់ម្ចាស់គ្រឹះស្ថានសេវាកំសាន្តសប្បាយ នៅពេលដែលក្រុមការងារដែលត្រូវចុះទៅអប់រំនៅតាមគ្រឹះស្ថាននីមួយៗ កន្លងមកគឺជួនកាលមានការសហការមិនពេញលេញ និងជួនកាលមិនព្រមសហការតែម្តង។ លោកក៏បន្ថែមទៀតថាលោកបានធ្វើការស្នើសុំដល់គណៈអភិបាលរាជធានី

ភ្នំពេញ ដែលជាប្រធានគណកម្មាធិការអេដស៍រាជធានីជួយធ្វើអន្តរាគមន៍ជាមួយសេវាកំសាន្តមួយចំនួន ដែលសហការមិនពេញលេញ មិនសហការ។ ជាលទ្ធផល ឯកឧត្តមអភិបាលរាជធានីភ្នំពេញបាន ចំណារឯកភាពលើលិខិតស្នាម និងបានបញ្ជូនដល់គ្រប់សាលាខណ្ឌដែលពាក់ព័ន្ធជួយសហការធ្វើ អន្តរាគមន៍ និងមានបញ្ជីឈ្មោះរបស់ហាងនីមួយៗ។ ចំពោះហាងណាដែលមិនព្រមសហការត្រូវធ្វើ កំណត់ត្រាបញ្ជូនមកលេខាធិការដ្ឋានអេដស៍រាជធានីដើម្បីធ្វើការដោះស្រាយបន្ត។ ជាមួយគ្នានោះដែរ ឯកឧត្តមអភិបាល ក៏បានស្នើឱ្យមានកិច្ចប្រជុំគណកម្មាធិការអេដស៍សង្កាត់ ខណ្ឌ ដើម្បីពិនិត្យតាមដាន ការអនុវត្តការងារនៅតាមសង្កាត់ ខណ្ឌនីមួយៗ។ នាឱកាសនោះដែរលោកក៏បានស្នើដល់អង្គការដៃគូ ត្រូវមានផែនការសកម្មភាពច្បាស់លាស់ក្នុងការចុះផ្សព្វផ្សាយអប់រំ និងត្រូវមានទំនាក់ទំនងជាមួយចៅ សង្កាត់ ខណ្ឌដើម្បីងាយស្រួលសហការ។

ជាមួយគ្នានោះ លោកវេជ្ជ. ទេព ណាវុធ ប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និង ស្រាវជ្រាវ បានមានមតិបញ្ជាក់ថា បទបង្ហាញស្តីពីការបង្ការទៅលើក្រុមប្រជាជនប្រឈមមុខខ្ពស់របស់ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដាក់ក្នុងរបាយការណ៍វឌ្ឍនភាព និង សមិទ្ធផលនៃការឆ្លើយតបទៅនឹងការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជាសម្រាប់កិច្ច ប្រជុំពេញអង្គលើកទី២ ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៩នេះ។

តំណាងអង្គការ KHANA ក៏បានស្នើសុំដល់សាលាក្រុងចេញលិខិតស្នាមសម្រាប់អង្គការដៃគូ ដែលធ្វើការតាមបណ្តាហាងនានាក្នុងមូលដ្ឋាន ប្រសិនបើមានហាងណាមិនព្រមសហការនឹងកត់ត្រា ជូនលេខាធិការដ្ឋានអេដស៍រាជធានី។ ដោយឡែកចំពោះ ក្រុម MSM EW PWID ខាងអង្គការមានថវិកា សម្រាប់អនុវត្តសកម្មភាពចុះអប់រំ ចំណែកក្រុម PWUD មិនមានថវិកា ថាតើយើងគួរមានកញ្ចប់ថវិកា ណាដើម្បីធ្វើជាមួយគាត់បន្ថែម?

ជាការឆ្លើយតប ឯកឧត្តមប្រធានអង្គប្រជុំ បានជម្រាបជូនថា គួរបញ្ចូលការផ្សព្វផ្សាយអំពីជំងឺ អេដស៍ និងគ្រឿងញៀនជាមួយគ្នាដោយប្រើកញ្ចប់ថវិកាតែមួយ និងលើកកិច្ចប្រជុំជាមួយក្រុមការងារ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងគ្រឿងញៀន។

រីឯតំណាងអង្គការ AHF ក៏បានលើកឡើងពីក្តីបារម្ភចំពោះកំណើនប្រេវ៉ាឡង់ចំពោះក្រុម MSM និងយុវវ័យ ជាពិសេសដៃគូស្នេហា។ របាយការណ៍បង្ហាញថា ការប្រើប្រាស់ស្រោមអនាម័យនៅ មានចំនួនតិចតួចគឺត្រឹមតែ ២៧,២% សម្រាប់ឆ្នាំ២០២០ខាងមុខ។ ខាងអង្គការក៏មានកម្មវិធីលើក កម្ពស់ក្មេងស្រីដើម្បីអនាគតភ្លឺស្វាង ដើម្បីយល់ដឹងពីជំងឺអេដស៍ គ្រឿងញៀន និងអំពើហិង្សា។ ជាមួយ គ្នានោះដែរ អង្គការ AHF មានរថយន្តចល័តសម្រាប់ធ្វើសកម្មភាពចុះផ្សព្វផ្សាយ អប់រំ ធ្វើតេស្តឈាម និងចែកស្រោមអនាម័យដល់នាយទាហាន និងក្រុមប្រឈមមុខខ្ពស់ តាមបណ្តាភូមិភាគនានា និងតាម បណ្តាខេត្តមួយចំនួន ដូចជា ខេត្តព្រៃវែង និងខេត្តត្បូងឃ្មុំ ហើយរកឃើញអ្នកមានតេស្តវិជ្ជមានចំនួន ០៨នាក់។

**ប្រធានបទទី២៖** បទបង្ហាញពីផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ ពហុវិស័យ ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៥ (២០១៩-២០២៣) ដោយលោកវេជ្ជ. ទេព ណារុជ ប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ៖

ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ ពហុវិស័យ ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ជាឯកសារណែនាំសម្រាប់គ្រប់វិស័យ និងដៃគូពាក់ព័ន្ធចាប់យកសកម្មភាពទៅអនុវត្ត និងដើម្បីចូលរួមសម្រេចឱ្យមានប្រសិទ្ធភាពក្នុងការឆ្លើយតបទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយបានចែកពីគោលបំណងជាក់លាក់ដូចខាងក្រោម៖

- គោលការណ៍៖ ភាពជាម្ចាស់ការតម្រឹមរបស់ជាតិជាមួយ SDGs ឯកសាររដ្ឋាភិបាលសំខាន់ៗផ្សេងទៀតផ្តោតលើមនុស្សជាសំខាន់ គ្មាននរណាម្នាក់ត្រូវទុកចោលនោះឡើយ យេនឌ័រ ភាពយុត្តិធម៌ កិច្ចសហការពហុវិស័យ អន្តរវិស័យ និងការចូលរួមរបស់អង្គការសង្គមស៊ីវិល។
- ចក្ខុវិស័យ៖ប្រជាជនទាំងអស់នៃប្រទេសកម្ពុជាគ្មានជំងឺអេដស៍ និងមានសុខភាព និងសុខុមាលភាពប្រសើរ។
- បេសកកម្ម៖ដឹកនាំប្រព័ន្ធមួយឆ្ពោះទៅរកការឆ្លើយតបប្រកបដោយថាមពល សមាហរណកម្ម និងចីរភាព ចំពោះការឆ្លើយតបនឹងជំងឺអេដស៍។
- គោលដៅ៖ឈានឆ្ពោះទៅរកការបញ្ចប់ជំងឺអេដស៍ដែលជាការគំរាមកំហែងសុខភាពសាធារណៈនៅឆ្នាំ២០២៥។

ផែនការយុទ្ធសាស្ត្រជាតិលើកទី៥ មានគោលដៅចំនួន៤ ហើយគោលដៅនីមួយៗមានគោលបំណងជាក់លាក់សម្រាប់អនុវត្ត និងលទ្ធផលរំពឹងទុក៖

<u>គោលដៅទី១</u>៖ កាត់បន្ថយការឆ្លងមេរោគអេដស៍ថ្មីក្នុងមួយឆ្នាំឱ្យនៅក្រោម ៧២០នាក់ និងឈានដល់ ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥ តាមរយៈការឆ្លើយតបពហុវិស័យ។

- គោលបំណង៖
  - ក្រសួងនានា ស្ថាប័នសម្របសម្រួល និងផ្នែកផ្សេងៗទៀត រួមមាន អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការបង្ការដល់ប្រជាពលរដ្ឋទាំងអស់ដើម្បីរួមចំណែកក្នុងការកាត់បន្ថយការឆ្លងថ្មី។
  - អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងដៃគូជានាថា មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នឹងទទួលបានការគាំទ្រ និងជំនួយគ្រប់គ្រាន់ពីអ្នកពាក់ព័ន្ធនានា ពីក្នុងវិស័យផ្សេងៗទៀត ដើម្បីសម្រេចបានគោលដៅ ៩៥-៩៥-៩៥។
  - ដៃគូទាំងអស់ជួយសម្រួលពង្រឹងតួនាទី និងមុខងាររបស់អង្គការសង្គមស៊ីវិលដើម្បីឱ្យពួកគេអាចគាំទ្រផ្នែកការបង្ការបានល្អ និងកិច្ចខិតខំប្រឹងប្រែងពាក់ព័ន្ធដែលដឹកនាំដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ។

- លទ្ធផលៈ
    - នៅឆ្នាំ២០២៥ ការឆ្លងថ្មីនឹងត្រូវបានកាត់បន្ថយពី៨៨០នាក់ ក្នុងមួយឆ្នាំ(ឆ្នាំ២០១៨) មកនៅក្រោមចំនួន ៧២០នាក់ក្នុងមួយឆ្នាំនៅឆ្នាំ២០២៥។ ៩៥% នៃPLHIV ដែលបានប៉ាន់ស្មានសរុបដឹងពីស្ថានភាពមេរោគអេដស៍របស់ពួកគេ ៩៥% នៃអ្នកដែលបានដឹងពីស្ថានភាពមេរោគអេដស៍ទទួលបានការព្យាបាលហើយ ៩៥% នៃPLHIV ដែលទទួលបានការព្យាបាលមានបន្ទុកមេរោគក្នុងឈាមទាប។

<u>គោលដៅទី២</u>៖ ដាក់បញ្ចូលការឆ្លើយតបមេរោគអេដស៍ក្នុងប្រព័ន្ធសុខាភិបាល ក្រសួងពាក់ព័ន្ធ និងស្ថាប័នសម្របសម្រួលថ្នាក់ជាតិ ។

- គោលបំណង៖
    - ធានាថាក្រសួងសុខាភិបាល មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងដៃគូនានាធ្វើការរួមគ្នា ដើម្បីអនុវត្តការវាយតំលៃលើការធ្វើសមាហរណកម្មការងារអេដស៍ ហើយដើម្បីបង្កើតនូវក្របខ័ណ្ឌការងាររួមមួយសម្រាប់ការធ្វើសមាហរណកម្មការងារអេដស៍ទៅក្នុងប្រព័ន្ធសុខាភិបាល។
    - ធានាថាក្រសួង និងដៃគូពាក់ព័ន្ធនានាបញ្ចូលការងារអេដស៍ទៅក្នុងផែនការ និងកម្មវិធីរបស់គេ។ ធានាអោយបាននូវ synergy ការធ្វើឱ្យមានសុខដុមបនីយកម្ម និងការតម្រឹម (alignment)។
    - ធានាការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរថ្នាក់ជាតិ ស្ថាប័ន ទីភ្នាក់ងារ ឬគណៈកម្មការផ្សេងទៀត ដើម្បីដាក់បញ្ចូលបទអន្តរាគមន៍ការងារអេដស៍ដោយផ្អែកលើភស្តុតាងជាមូលដ្ឋាននៅក្នុងគោលនយោបាយ និងកម្មវិធីរបស់ពួកគេ។
- លទ្ធផលៈ
    - នៅឆ្នាំ២០២៣ ការវាយតម្លៃ និងក្របខ័ណ្ឌការងារសម្រាប់ធ្វើសមាហរណកម្មការងារអេដស៍ទៅក្នុងប្រព័ន្ធសុខាភិបាលត្រូវបានបង្កើតឡើង ដោយមានការចូលរួមយ៉ាងពេញលេញពីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងសុខាភិបាល មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងដៃគូនានា ហើយអនុសាសន៍នានាត្រូវបានអនុវត្ត។

គោលដៅទី៣៖ ពង្រឹកកិច្ចគាំពារសង្គម និងលើកកម្ពស់បរិយាកាសគាំទ្រសម្រាប់ការបង្កើនលទ្ធភាពទទួលបានសេវាសុខភាព សេវាផ្លូវច្បាប់ និងសង្គមសម្រាប់ PLHIV and KPs ។

- គោលបំណង៖
  - ពង្រឹកគ្របដណ្ដប់សម្រាប់យន្តការគាំពារសង្គម ធ្វើឱ្យមានលទ្ធភាពទទួលបានសុខភាព និងសេវាកម្មសង្គមផ្សេងទៀតដែលទាក់ទងនឹងមេរោគអេដស៍។ ក្របខណ្ឌច្បាប់ និងគោលនយោបាយមានលក្ខណៈទូលំទូលាយ ក្នុងការទទួលបានសេវាសម្រាប់ប្រជាជនប្រឈមមុខ ជាពិសេសសម្រាប់មនុស្សវ័យក្មេង។
  - ក្របខណ្ឌការងារផ្នែកច្បាប់ និងគោលនយោបាយមានលក្ខណៈកាន់តែទូលំទូលាយ ក្នុងការគាំទ្រការផ្ដល់សេវាកម្មសម្រាប់ប្រជាជនគន្លឹះទាំងអស់ និងLGBTIQ ជាពិសេសសម្រាប់យុវវ័យ។
- លទ្ធផល៖
  - ១០០% នៃPLHIV បានគ្របដណ្ដប់ដោយយន្តការគាំពារសង្គមនៅឆ្នាំ២០២៣។

គោលដៅទី៤៖ បង្កើនការផ្ដល់ថវិការដ្ឋាភិបាលឱ្យបាន៥០% សម្រាប់កម្មវិធីឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ និងវិភាជន៍ហិរញ្ញវត្ថុរាជរដ្ឋាភិបាលដល់សង្គមស៊ីវិលដែលធ្វើការងារ ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍។

- គោលបំណង៖
  - បង្កើនការផ្ដល់ថវិការដ្ឋាភិបាលឱ្យបាន៥០% សម្រាប់កម្មវិធីឆ្លើយតបជំងឺអេដស៍នៅក្នុងឆ្នាំ២០២៣។
  - ជំរុញវិភាជន៍ហិរញ្ញវត្ថុរដ្ឋាភិបាលដល់សង្គមស៊ីវិលដែលបំរើការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍។
- លទ្ធផល៖
  - ធ្វើឱ្យមាននិរន្តរភាពហិរញ្ញវត្ថុឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅក្នុងកម្ពុជា។

**ប្រធានបទទី៣**៖បទបង្ហាញស្ដីអំពីរបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលនៃការឆ្លើយតបជាតិទូលំទូលាយ និងពហុវិស័យទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំឆមាសទី២ ឆ្នាំ២០១៩របស់ក្រសួង ស្ថាប័នដែលជាសមាជិកដោយលោកវេជ្ជ.**លី ចាន់វ៉ារ៉េជ** អនុប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ របាយការណ៍ដែលបានទទួលតាមក្រសួង រាជធានី ខេត្តក្រុងសម្រាប់បង្ហាញក្នុងកិច្ចប្រជុំពេញអង្គលើកទី២ ៖

- វឌ្ឍនភាព និងសមិទ្ធផលនៃការដឹកនាំសម្របសម្រួល និងចលនាប្រភពធនធាន
- វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍
- វឌ្ឍនភាព និងសមិទ្ធផលនៃការថែទាំ និងព្យាបាល

- វឌ្ឍនភាព និងសមិទ្ធផលនៃការកាត់បន្ថយផលប៉ះពាល់ និងការរើសអើង
- វឌ្ឍនភាព និងសមិទ្ធផលនៃការបង្កើនបរិយាកាសគាំទ្រការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍
- វឌ្ឍនភាព និងសមិទ្ធផលនៃការតាមដាន និងវាយតម្លៃ

សរុបក្នុងនោះទទួលបានរបាយការណ៍ពីក្រសួងរាជធានីចំនួន ២៣ក្រសួង និង២៥រាជធានីខេត្ត នៅឡើយមិនទាន់ទទួលរបាយការណ៍ពីខាងក្រសួងយុត្តិធម៌ ក្រសួងពាណិជ្ជកម្ម ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការអាកាសចរណ៍ស៊ីវិល ក្រសួងមុខងារសាធារណៈ និងក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ។

ក្រោយពីបង្ហាញចប់ ឯកឧត្តមប្រធានអង្គប្រជុំ ក៏បានជម្រាបជូនដល់សមាជិក សមាជិកានៃអង្គប្រជុំថា នៅកិច្ចប្រជុំពេញអង្គលើកទី២ ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៩ខាងមុខនេះនឹងមានផ្តល់ប័ណ្ណសរសើរដល់ក្រសួង រាជធានី ខេត្តដែលបានផ្តល់របាយការណ៍សកម្មភាព ហើយការផ្តល់ជូននេះទៅតាមកំរិតនៃការវាយតំលៃរបស់គណៈកម្មាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**មតិបូកសរុបរបស់ឯកឧត្តមប្រធានៈ**

- នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ ត្រូវផ្ញើរបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលនៃការឆ្លើយតបជាតិទូលំទូលាយ និងពហុវិស័យទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំឆមាសទី២នេះ ចូលក្នុង Telegram របស់ក្រុមប្រឹក្សាបច្ចេកទេស។
- ធានាឱ្យបាននូវគោលការណ៍ស្រោមអនាម័យ១០០% ឱ្យកាន់តែប្រសើរ។
- អង្គការសង្គមស៊ីវិល ត្រូវធ្វើផែនការប្រចាំត្រីមាសរបស់ខ្លួន ដាក់ជូនទៅសង្កាត់ ខណ្ឌមុនធ្វើសកម្មភាពអ្វីមួយ។
- នៅកិច្ចប្រជុំលើកក្រោយ យើងនឹងរកយន្តការណាមួយដើម្បីសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ទាក់ទងនឹងជំរុញការផ្សព្វផ្សាយដែលមានប្រសិទ្ធិភាព ជូនថ្នាក់ដឹកនាំសម្រេច។

មុននឹងបញ្ចប់ ឯកឧត្តមប្រធាន បានថ្លែងអំណរអរគុណចំពោះវត្តមាន ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលបានអញ្ជើញចូលរួម ចែករំលែកនូវបទពិសោធន៍ក៏ដូចជាមតិយោបល់ល្អៗជូនអង្គសិក្ខាសាលា និងបានប្រសទ្ធិពរដល់សមាជិក សមាជិកាទាំងអស់ឱ្យទទួលបាននូវពុទ្ធពរទាំង៤ប្រការ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ ជាមួយគ្នានោះ ឯកឧត្តមបានជម្រាបផងដែរថា អង្គសិក្ខាសាលារបស់ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១០នឹងប្រព្រឹត្តទៅនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង១១ និង៣០នាទី ថ្ងៃ ខែ ឆ្នាំ ដដែល ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត៕

**ឧបសម្ព័ន្ធ៖**

- បញ្ជីវត្តមានអ្នកចូលរួម
- ឯកសារបទបង្ហាញផ្សេងៗ

ថ្ងៃពុធ ២រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៩

បានឃើញ និងពិនិត្យផ្ទៀងផ្ទាត់
**អគ្គលេខាធិការ**

**ឈឹម យិនដារ៉េត**

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋាន ទាក់ទង និងចលនាប្រភពធនធាន

**ទេជ្ជ. ហ្សួតសេរីវឌ្ឍ**

អ្នកធ្វើរបាយការណ៍

វេជ្ជ.កុយ តារាវន្ត